# ប្រវត្តិភ្នំប្រុស ភ្នំស្រី



ព្រះពុទ្ធបដិមាករនៅចេតិយភ្នំស្រី (រូបរបស់ សុក សូពុទ្ធី, កម្ពុជា, មិនា ២០១០)

ប្រទេសកម្ពុជាត្រូវបានគេចាត់ទុកថា ជាប្រទេសដែលស្ត្រីមានតួនាទីយ៉ាងសំខាន់ ។ បណ្ដាអ្នកស្រាវជ្រាវទាំងឡាយ ដែលសិក្សាអំពីវប្បធម៌ខ្មែរ បានចាប់អារម្មណ៍លើរឿងព្រេងមួយចំនួន ជាពិសេសរឿងព្រេងដែលពាក់ព័ន្ធនឹងប្រវត្តិភ្នំប្រុស ភ្នំស្រី នៅខេត្តកំពង់ចាម ។ តាមរយៈរឿងព្រេងនិទានទាំងនេះ គេយល់ថា ស្ត្រីខ្មែរមិនគ្រាន់តែតំណាងឲ្យភាពទន់ភ្លន់តែប៉ុណ្ណោះទេ ក៏ប៉ុន្តែមានបញ្ញាញាណឈ្លាសវៃ ព្រមទាំងល្បិចកលថែមទៀតផង ។ ដោយសារគុណសម្បត្តិទាំងនោះហើយ ទើបពួកគេរមែងតែទទួលជ័យជំនះលើបុរសជានិច្ច ។



ភ្នំស្រីនៅខេត្តកំពង់ចាម (១៩៩៣)



ចេតិយភ្នំស្រី (រូបរបស់ សុក សូពុទ្ធី, កម្ពុជា, មិនា ២០១០)

ភស្តុតាងនៃឧត្តមភាព ឬអត្ថិភាពរបស់ស្ត្រីខ្មែរ ត្រូវបានគូសបញ្ជាក់តាមរយៈរឿងព្រេងស្តីពីការប្រណាំងប្រជែងរវាងស្ត្រី និងបុរស ដើម្បីកសាងភ្នំ ដែលមានខ្លឹមសារដោយសង្ខេបដូចតទៅ ៖

‹ ក្នុងសម័យដ៏យូរលង់ ដែលគេមិនអាចកំណត់ពេលវេលាបាន ថ្ងៃមួយស្ត្រី និងបុរសបានបបួលគ្នា ដើម្បីលើកដីពូនជាភ្នំដោយដាក់លក្ខខណ្ឌថា ភ្នំដែលនឹងសាងឡើងនោះ គេត្រូវប្រើពេលត្រឹមតែមួយយប់ប៉ុណ្ណោះ ។ ហើយបើភាគីណាឈ្នះ ដោយសាងភ្នំរួចមុនគេភាគីនោះនឹងអាចសម្រេចជោគវាសនារបស់ភាគីម្ខាង ទៀត ។ មានន័យថា ភាគីណាដែលចាញ់ នឹងត្រូវចូលស្តីភាគីមួយទៀតវិញ ដើម្បីធ្វើជាដៃគូប្រចាំជីវិតមិនថា ភាគីប្រុស ឬភាគីស្រីទេ ។ កន្លងមកគឺភាគីស្ត្រីទេដែលចូលស្តីដណ្តឹងប្រុសធ្វើជាប្តី តាមគន្លងប្រពៃណីដូនតា ។

ជាការពិតណាស់ក្នុងការពូនភ្នំ ពួកស្ត្រីដែលមានកម្លាំងខ្សោយជាងបុរស តែត្បិតមានភាពឈ្លាសវៃ ក៏បានឈ្នះបុរសជាស្ថាពរដោយកលល្បិចទៅវិញ ។ ដោយហេតុថាការប្រណាំប្រជែងកំពុងប្រព្រឹត្តទៅមិនទាន់ដល់ពេលកំណត់ដែលថាចប់ពេល ផ្កាយព្រឹករះផងស្រាប់តែពួកស្ត្រីនាំគ្នាដុតគោមបង្ហោះលើមេឃ ធ្វើឲ្យប្រុសៗស្មានថា ជាផ្កាយព្រឹករះប្រាកដមែន ហើយពួកគេក៏នាំគ្នាឈប់សម្រាកដោយដេករហូតដល់ភ្លឺតែម្តង ។



ភ្ញៀវទេសចរកំពុងឡើងទៅទស្សនាចេតិយភ្នំស្រី (រូបរបស់ សុក សុពុទ្ធី, កម្ពុជា, មិនា ២០១០)

ចំណែកខាងស្រីវិញ ក្រោយពីបង្ហោះគោមរួច ពួកគេក៏នាំគ្នាម្នីម្នាខិតខំពូនភ្នំរហូតដល់រួចរាល់ជាស្ថាពរ ។ ដូច្នេះហើយក្រោយពីភ្នាល់ចាញ់ពួកស្ត្រីៗក៏ឈប់នាំគ្នាចូល ស្ដីដណ្ដឹងប្រុសៗ ធ្វើជាគូដូចមុនៗទៀត ។ ចាប់តាំងពីពេលនេះមក គឺបុរសទេដែលត្រូវស្ដីដណ្ដឹងស្ត្រីភេទធ្វើជាដៃគូម្ដងវិញ ហើយស្ថានភាពនេះនៅតែស្ថិតស្ថេររហូតដល់សព្វថ្ងៃ › ។

ខាងលើនេះគឺជារឿងដំណាលពាក់ព័ន្ធទៅនឹងការពូនដីសាងភ្នំ ប្រុស ភ្នំស្រី នៅខេត្តកំពង់ចាម ។ ដោយឡែក នៅមានរឿងព្រេងនៅតាមបណ្ដាខេត្តមួយចំនួនទៀត ដែលទាក់ទិនទៅនឹងការលើកធ្វើប្រាសាទប្រុស និងប្រាសាទស្រី ដែលមានខ្លឹមសារដូចគ្នា ។ ឧទាហរណ៍ទាំងប៉ុន្មានខាងលើនេះ កាន់តែឆ្លុះបញ្ចាំងឲ្យឃើញកាន់តែច្បាស់ពីតួនាទីរបស់ស្ត្រីភេទ និងសារៈប្រយោជន៍នៃរឿងបុរាណទាំងនោះ ក្នុងការពន្យល់អំពីការកកើតទឹកដី ឬក៏ស្ថានភាពរបស់ប្រាង្គប្រាសាទខ្មែរមួយចំនួន ដែលទ្រុឌទ្រោម ហើយគេរមែងតែជួបប្រទះក្នុងព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃនេះ ៕ (ម.ត្រាណោ)